**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៣ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការទទួលស្គាល់ វិទ្យាស្ថាន សហព័ន្ធ អ៊ីរ៉ុប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី–១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ២៦៣៦ អយក.ឧស ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៦

# ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្ដមសិក្សាឯកជនមួយ ដែលមានឈ្មោះថា វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប " Institute of European Union " ហៅកាត់ជាភាសាខ្មែរ " វ.ស.អ " និងហៅកាត់ជាភាសាអង់គ្លេស I.E.U ។

**មាត្រា ២ :** វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប មានទីតាំងស្ថិតនៅ អគារលេខ ១៧៣ស្ទួន ផ្លូវលេខ ១៨២ សង្កាត់ផ្សារដេប៉ូ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ធ្វើការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ និងបរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ និងបរិញ្ញាបត្រជាន់ខ្ពស់ សិក្សាស្រាវជ្រាវ រយៈពេល ២ឆ្នាំ ជាមធ្យម ។ ក្នុងរយៈពេល បីខែ បន្ទាប់ពីថ្ងៃចាប់ដំណើរការ វិទ្យាស្ថាននេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤ :** វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប មានមហាវិទ្យាល័យចំនួន ០៤ :

- មហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងភាសាបរទេស
- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន
- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងនីតិសាស្ត្រ
- មហាវិទ្យាល័យគ្រប់គ្រង និងទេសចរណ៍

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកសាខា មហាវិទ្យាល័យ មុខជំនាញ ឬប្រភេទបណ្ដុះបណ្ដាលដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្ដែង នៃវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧ :** វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋានដែលពាក់ព័ន្ធនឹងការងារបណ្ដុះបណ្ដាល របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ឱ្យបានល្អប្រសើរ ។

**មាត្រា ៨ :** នាយកនៃវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប មានភារកិច្ចទទួលខុសត្រូវ ចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងវិទ្យាស្ថាន ធានាឱ្យបាននូវសុវត្ថិភាព សណ្ដាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្ដមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

/ម

**មាត្រា ៩ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់វិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងឯកទេស ដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួង អប់រំ យុវជន និងកីឡា។

**មាត្រា ១០ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងវិទ្យាស្ថាន សហព័ន្ធ អឺរ៉ុប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១០
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ